00192138

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C20 I/21

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០២)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 05 / 2008
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ: ២០ ឧសភា ២០០៨

---

# សេចក្តីណែនាំអំពីសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលសវនាការបណ្តឹងឧទ្ធរណ៍ចំពោះដីកាឃុំខ្លួនបណ្តោះអាសន្ន

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង ធីរិទ្ធ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 26 / 05 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA KOSAL

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គីមសួន
ឡៅ ជុនធី
នី ចាន់ធី
គង់ ពិសី
Silke Studzinsky

**សហមេធាវីការពារក្តី**
ផាត់ ពៅសីាន
Diana ELLIS

PRE-TRIAL CHAMBER PRELIMINAIRE

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

១. **អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា("អ.វ.ត.ក") យល់ឃើញថា ដើម្បីផលប្រយោជន៍ក្នុងការធានាកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័ស និង ដើម្បីផលប្រយោជន៍នៃការធ្វើសេចក្តីសន្និដ្ឋានដែលពាក់ព័ន្ធ និងដើម្បីជៀសវាងការរាំងស្ទះដល់សវនាការ វាជាការសមស្របដែលអង្គបុរេជំនុំជម្រះត្រូវចេញសេចក្តីណែនាំបន្ថែមដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមក្នុងសវនាការបណ្តឹងឧទ្ធរណ៍នេះ។

២. អង្គបុរេជំនុំជម្រះចង្អុលយោងតាមវាក្យខណ្ឌទី ៤៦ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនស្តីពីវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្នថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៨។

៣. វិធាន ២៣(៧) នៃវិធានផ្ទៃក្នុងចែងថា "ជនរងគ្រោះដែលចូលរួមក្នុងនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិត្រូវបានតំណាងដោយមេធាវីជាតិ ឬ អន្តរជាតិដោយសហការជាមួយមេធាវីជាតិ"។ វិធាន ៧៧ ស្តីពីនីតិវិធីបណ្តឹងឧទ្ធរណ៍ និង ពាក្យសុំទៅអង្គបុរេជំនុំជម្រះចែងនៅក្នុងវាក្យខណ្ឌទី ៤ ថា "មេធាវីរបស់ភាគីអាចសុំមើលសំណុំរឿងរហូតដល់ថ្ងៃសវនាការ"។ វាក្យខណ្ឌទី ១០ នៃវិធានដដែលចែងថា: "បន្ទាប់ពីសហចៅក្រមរបាយការណ៍បានអានរបាយការណ៍ សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីអាចធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយសង្ខេប"។

៤. យោងតាមគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ កត្តាដែលសំខាន់នោះគឺ សហមេធាវីការពារក្តីគួរដឹងអំពីខ្លឹមសារនៃសេក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណីមុនថ្ងៃសវនាការ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញអំពីការកើនឡើងនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី និងជំហរខុសៗគ្នារបស់ភាគីទាំងនេះ។ អង្គបុរេជំនុំជម្រះក៏បានធ្វើការពិចារណាផងដែរអំពីលក្ខណៈបច្ចេកទេសនៃសារណាជាលាយលក្ខណ៍អក្សររបស់ភាគីទាំងអស់នៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍នេះ រួមទាំងភាគីដើមបណ្តឹងរដ្ឋប្បវេណីផង។

៥. ហេតុដូច្នេះ វិធានផ្ទៃក្នុងគួរត្រូវបានបកស្រាយថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានជ្រើសរើសមេធាវីឱ្យធ្វើជាតំណាង ត្រូវធ្វើការកត់សម្គាល់ដោយសង្ខេបរបស់ខ្លួន អំពីពាក្យសុំ ឬ បណ្តឹងឧទ្ធរណ៍ តាមរយៈមេធាវីរបស់ខ្លួន។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះណែនាំ:**

អនុលោមតាមវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុង រាល់សេចក្តីសន្និដ្ឋានផ្ទាល់មាត់ទាំងអស់ ក្នុងនាមឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី។

ភ្នំពេញ, ថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ប្រាក់ គឹមសាន